**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៣ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់ នូវការឆ្លងរាលដាល នៃជំងឺផ្តាសាយបក្សី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់របស់រដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្តាសាយបក្សី ។

គណៈកម្មការនេះមានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាប្រធាន |
| ២- តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

៧- តំណាងទីចាត់ការគយ និង រដ្ឋាករ — សមាជិក

៨- អភិបាលខេត្តក្រុងពាក់ព័ន្ធ — សមាជិក

៩- ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល — លេខាធិការ

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចទទួលខុសត្រូវរួម លើការណែនាំអនុវត្តទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សីសហការជាមួយអង្គការ FAO WHO OIE អង្គការជាតិ និងអន្តរជាតិផ្សេងទៀតតាមការចាំបាច់ និង ធ្វើរបាយការណ៍លំអិតជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារដែលអនុវត្តបាន និង ស្នើសុំយោបល់សំរេចពីរាជរដ្ឋាភិបាលក្នុងករណីមានការចាំបាច់ ។

**ប្រការ ៣ :** សមាជិកគណៈកម្មការអន្តរក្រសួងនេះត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិរៀបចំលេខាធិការដ្ឋានមួយដើម្បីជំនួយការងារដែលមានទីតាំង និងសមាសភាពកំណត់ ដោយឯកឧត្តមប្រធានគណៈកម្មការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីកសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីកសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និង សមាសភាពដូចចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាដូចតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៤*

*-ឯកសារ-កាលប្បវត្តិ*